# របាយការណ៍សវនកម្ម ក្រោមប្រធានបទ
# «ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់» របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ការិយបរិច្ឆេទ២០២៣

## របាយការណ៍សង្ខេប

យោងតាមគោលការណ៍សវនកម្មលើកិច្ចប្រតិបត្តិការដែលមានចែងក្នុងស្តង់ដា ISSAI300 សវនកម្មលើកិច្ចប្រតិបត្តិការ អនុវត្តដោយស្ថាប័នសវនកម្មកំពូលគឺជាការត្រួតពិនិត្យ ដោយឯករាជ្យ សត្យានុម័ត និងអាចជឿទុកចិត្តបាន ថាតើប្រព័ន្ធ កិច្ចប្រតិបត្តិ កម្មវិធីសកម្មភាព ឬការគ្រប់គ្រងរបស់រដ្ឋាភិបាលប្រព្រឹត្តទៅស្របតាមគោលការណ៍នៃភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងថាតើមានផ្នែកណាដែលអាចកែលម្អឱ្យប្រសើរថែមទៀត។ សវនកម្មលើកិច្ចប្រតិបត្តិការ គឺជាការស្វែងរកការផ្តល់នូវព័ត៌មានថ្មីៗ ការវិភាគ ឬការយល់ដឹងស៊ីជម្រៅប្រកបដោយភាពសមស្របដើម្បីផ្តល់អនុសាសន៍កែលម្អ។ ជាមួយគ្នានេះ វិស័យប្រៃសណីយ៍ត្រូវបានចាត់ទុកថាមានសក្តានុពលក្នុងការចូលរួមចំណែកទ្រទ្រង់អភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ដោយវិស័យនេះនឹងបង្កើតបានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដែលជួយសម្រួលដល់ដំណើរប្រព្រឹត្តទៅក្នុងផ្នែកសង្គម សេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី វិសាលភាពនៃការផ្តល់សេវាប្រៃសណីយ៍នៅមិនទាន់បានគ្របដណ្តប់ទូលំទូលាយនៅទូទាំងប្រទេសកម្ពុជានៅឡើយ ដូចជាការមិនទាន់អាចឆ្លើយតបបានពេញលេញ និងល្អប្រសើរទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អ្នកប្រើប្រាស់ និងការរកស៊ីទទួលទានលើវិស័យប្រៃសណីយ៍ ភាពយឺតយ៉ាវនៃបញ្ញើនាំឱ្យខូចគុណភាព ការបាត់របស់ ការវេចខ្ចប់មិនបានត្រឹមត្រូវ និងកង្វល់កន្លងមករបស់អ្នកប្រើប្រាស់លើសេវាប្រៃសណីយ៍។ល។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍២០២២-២០៣០ គឺជាប្រទីបនាំផ្លូវឆ្ពោះទៅរកការដោះស្រាយបញ្ហាប្រឈមក្នុងទិសដៅទាញយកផលប្រយោជន៍ពីការលានុវត្តភាពដែលបាន និងកំពុងលេចឡើង ហើយគោលនយោបាយនេះគឺជាឧបករណ៍ដែលបម្រើការដោះស្រាយបញ្ហាតូចចង្អៀត និងភាពនៅមានកម្រិតនៃការផ្តល់សេវាប្រៃសណីយ៍ក្នុងប្រទេសកម្ពុជាដែលមានចក្ខុវិស័យ «ការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទីផ្សារសេវាប្រៃសណីយ៍ ដើម្បីបម្រើធុរកិច្ចសហគ្រាស និងប្រជាជនប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងនវានុវត្តន៍សំដៅចូលរួមការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ»។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដែលទទួលបន្ទុកជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងវិស័យប្រៃសណីយ៍នៅកម្ពុជា ត្រូវរៀបចំការអនុវត្តគោលនយោបាយនេះឱ្យសម្រេចបានតាមគោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងរៀបចំ និងជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចង្អុលដោយគោលនយោបាយ។

ប្រធានបទសវនកម្ម «ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់» របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សម្រាប់ការិយបរិច្ឆេទ២០២៣ត្រូវបានធ្វើសវនកម្មក្នុងគោលបំណងធ្វើការវាយតម្លៃថា តើក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានដាក់ចេញ

គោលនយោបាយ យុទ្ធសាស្ត្រ ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលដែរឬទេ? កត្តាជំរុញលើកទឹកចិត្តធ្វើសវនកម្មដោយសារៈ អាណត្តិការងាររបស់អាជ្ញាធរសវនកម្មជាតិ ដែលផ្អែកតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា២ និងមាត្រា៩។ ប្រធានបទនេះក៏បានឆ្លុះបញ្ចាំងនូវភាពជាសារវន្ត និងហានិភ័យនៃកិច្ចប្រតិបត្តិការផងដែរ។ ជាមួយគ្នានេះ អាជ្ញាធរសវនកម្មជាតិក៏មានលទ្ធភាពអាចធ្វើសវនកម្ម និងការចូលរួមចំណែកដ៏មានសក្តានុពលក្នុងការលើកកម្ពស់កិច្ចប្រតិបត្តិការ ការផ្តល់សេវាឱ្យប្រសើរជាងមុន និងការផ្តល់អត្ថប្រយោជន៍ខ្ពស់ដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ប្រកបដោយប្រសិទ្ធភាព។

បន្ទាប់ពីបានចុះធ្វើសវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់» របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានខិតខំអនុវត្តយ៉ាងយកចិត្តទុកដាក់លើការអនុវត្តយុទ្ធសាស្ត្រ យន្តការ ផែនការសកម្មភាព ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយក្នុងការជួយបម្រើធុរកិច្ចសហគ្រាស និងប្រជាជន អនុវត្តប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល។ ទន្ទឹមនឹងនេះ ក៏នៅមានចំណុចខ្វះខាតគួរឱ្យកត់សម្គាល់មួយចំនួនដូចខាងក្រោម៖

១. ដំណើរការអនុវត្តយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់នៅមានកម្រិតដូចជា៖
   - ការរៀបចំបែបបទនៃដំណើរការត្រួតពិនិត្យ និងក្រមសីលធម៌របស់មន្ត្រីក្នុងការត្រួតពិនិត្យការងារសេវាកម្ម និងអាជីវកម្មប្រៃសណីយ៍
   - ការបង្កើតប្រព័ន្ធឌីជីថល(ថ្នាល)ដើម្បីត្រួតពិនិត្យតាមដានការគ្រប់គ្រងគុណភាពនៃការផ្តល់សេវាប្រៃសណីយ៍
   - ការវាយតម្លៃពីវឌ្ឍនភាពនៃការផ្តល់សេវាជាក់ស្តែងរបស់អ្នកផ្តល់សេវាប្រៃសណីយ៍ នៅមិនបានបន្សីគ្នារវាងសកម្មភាពដែលមានចែងក្នុងឧបសម្ព័ន្ធទី១នៃគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍

២. ដំណើរការនៃការអនុវត្តផែនការសកម្មភាពនៅមានកម្រិតដូចជា៖
   - ការបង្កើត និងអនុវត្តយន្តការសហការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ
   - ការពង្រឹងក្របខណ្ឌគតិយុត្ត
   - ការរៀបចំការបណ្តុះបណ្តាលធនធានមនុស្ស
   - ដំណើរការអនុវត្តគម្រោងនៅមិនទាន់មានផែនការសកម្មភាពលម្អិតសម្រាប់អនុវត្ត

៣. ការបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តគោលនយោបាយនៅមានកម្រិត ដូចជា ៖
   - ការពុំទាន់កំណត់សូចនាករច្បាស់លាស់សម្រាប់តាមដាន និងវាយតម្លៃ
   - ការពុំទាន់ធ្វើរបាយការណ៍វឌ្ឍនភាពដែលត្រូវធ្វើឡើងជារៀងរាល់ឆ្នាំជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ការវាយតម្លៃលើរបាយការណ៍អនុវត្តសកម្មភាពអាទិភាព
- ការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ កំណត់វិធីសាស្ត្រស្រាវជ្រាវ ប្រមូល និងវិភាគទិន្នន័យ និងយន្តការរាយការណ៍។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ« ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ »របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានដាក់ចេញគោលនយោបាយយុទ្ធសាស្ត្រ ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់អាចនៅមានកម្រិតក្នុងការជួយជំរុញការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព និងទាន់ពេលនៅឡើយ។

ឆ្លងតាមលទ្ធផល និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ អាជ្ញាធរសវនកម្មជាតិសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. ក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍គួរជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអនុវត្តយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍។

២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍គួរជំរុញការអនុវត្តផែនការសកម្មភាពឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

៣. ក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍គួរជំរុញការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

## មតិបំភ្លឺរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ : ៣០២៦ ប្រ.ទ.អប

ថ្ងៃ ពុធ ៥ រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២៤

**គោរពជូន**

**លោកជំទាវអគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ**

**កម្មវត្ថុ** : សេចក្តីបំភ្លឺលើរបាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់» នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សម្រាប់ការិយបរិច្ឆេទ២០២៣។

**យោង** : លិខិតលេខ០៨២/២៤ អសជ/សណាធ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ របស់អាជ្ញាធរសវនកម្មជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **លោកជំទាវអគ្គសវនករ** មេត្តាជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានទទួលរបាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់» នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សម្រាប់ការិយបរិច្ឆេទ២០២៣ ដែលអាជ្ញាធរសវនកម្មជាតិបានរៀបចំផ្ញើមកក្រសួងក្រោយពី គណៈប្រតិភូនៃអាជ្ញាធរសវនកម្មជាតិបានចុះមកបំពេញការងារសវនកម្មនៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នាពេលកន្លងមក។

ក្នុងន័យនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានរៀបចំសេចក្តីបំភ្លឺលើរបាយការណ៍សវនកម្មខាងលើ ដោយផ្តោតលើលទ្ធផលសវនកម្មដែលពាក់ព័ន្ធ (១) ដំណើរការអនុវត្តយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ (២) ដំណើរការនៃការអនុវត្តផែនការសកម្មភាព និង (៣) ការបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តគោលនយោបាយ ដូចមានគោរពជូនភ្ជាប់មកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវអគ្គសវនករ** មេត្តាពិនិត្យ និងបន្តនីតិវិធីដោយអនុគ្រោះ។

សូម **លោកជំទាវអគ្គសវនករ** មេត្តាទទួលនូវការគោរពពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ជា វ៉ាន់ដេត**

GO.gov.KH

សូមទាញយកឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សេចក្តីបំភ្លឺលើរបាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់» នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់ការិយបរិច្ឆេទ២០២៣

**ការបំភ្លឺលើលទ្ធផលសវនកម្ម ១. ដំណើរការអនុវត្តយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់**

ក្នុងការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យប្រៃសណីយ៍ ជាពិសេសលើយុទ្ធសាស្ត្រស្តីពីការបង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការការពារអ្នកប្រើប្រាស់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ក.ប.ទ.) បាននិងកំពុងយកចិត្តទុកដាក់លើការអនុវត្តកិច្ចការសំខាន់ៗដំណាលគ្នាដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រៃសណីយ៍ ដោយក្នុងនោះ កំណត់គោលការណ៍ វិធាន និងយន្តការនៃការគ្រប់គ្រងវិស័យប្រៃសណីយ៍ ដើម្បីធានាការធ្វើអាជីវកម្មប្រៃសណីយ៍ និងផ្តល់សេវាប្រៃសណីយ៍ប្រកបដោយគុណភាព តម្លៃសមរម្យ បរិយាបន្ន និងអាចជឿទុកចិត្តបាន។ សេចក្តីព្រាងច្បាប់នេះបានចង្អុលដល់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលបម្រើឱ្យការគ្រប់គ្រងលើការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់។ ក្នុងពេលដំណាលគ្នានៃការរៀបចំសេចក្តីព្រាងច្បាប់ ក.ប.ទ. បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសសំខាន់ចំនួន៣ គឺ (១) ប្រកាសស្តីពីការគ្រប់គ្រងគុណភាពសេវាប្រៃសណីយ៍ (២) ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតសេវាប្រៃសណីយ៍ និង (៣) ប្រកាសអន្តរក្រសួងស្តីពីតម្លៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតសេវាប្រៃសណីយ៍។ ឯកសារបទដ្ឋានគតិយុត្តខាងលើ ក្រសួងបានពិគ្រោះយោបល់ជាបន្តបន្ទាប់ ក្នុងនោះ បានពិគ្រោះយោបល់ផ្ទៃក្នុង និងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ប្រតិបត្តិករប្រៃសណីយ៍ និងស្ថាប័នអន្តរជាតិ រួមមាន សហភាពប្រៃសណីយ៍សកល សហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក និងប្រទេសជាដៃគូសហការ (ចិន ជប៉ុន អូស្ត្រាលី) ដើម្បីប្រមូលធាតុចូល។
- ការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសេវាប្រៃសណីយ៍ នឹងបង្កើតបានមូលដ្ឋានសម្រាប់គ្រប់គ្រងការងារវាយតម្លៃលើវឌ្ឍនភាពនៃការផ្តល់សេវាជាក់ស្តែងរបស់ប្រតិបត្តិករប្រៃសណីយ៍។ ដូច្នេះ ក.ប.ទ. នឹងខិតខំជំរុញការរៀបចំសេចក្តីព្រាងប្រកាសនេះ ឱ្យបានរួចរាល់។ ប៉ុន្តែ បើទោះបីជាស្ថិតក្នុងដំណាក់កាលនៃការរៀបចំសេចក្តីព្រាងប្រកាសនេះក៏ដោយ ក៏អគ្គនាយកដ្ឋានប្រៃសណីយ៍បានរៀបចំយន្តការនៃការវាយតម្លៃពីស្ថានភាពនៃការផ្តល់សេវាប្រៃសណីយ៍របស់

ប្រតិបត្តិករនានា តាមរយៈការរៀបចំការធ្វើអង្កេតស្តីពីបច្ចុប្បន្នភាពនៃការផ្តល់សេវាប្រៃសណីយ៍ប្រចាំឆ្នាំ ដើម្បីស្វែងយល់ ផ្សព្វផ្សាយ និងកែលម្អ ក្នុងគោលបំណងលើកកម្ពស់ការផ្តល់សេវាប្រៃសណីយ៍ជូនអ្នកប្រើប្រាស់។ ក្រៅពីនេះ អគ្គនាយកដ្ឋានប្រៃសណីយ៍ក៏បានរៀបចំការចុះពិនិត្យតាមដានការប្រតិបត្តិតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ ក៏ដូចជាគុណភាពនៃការផ្តល់សេវាប្រៃសណីយ៍ជាប់ជាប្រចាំ ដល់ទីតាំងជាក់ស្តែងរបស់ប្រតិបត្តិករប្រៃសណីយ៍។

- អគ្គនាយកដ្ឋានប្រៃសណីយ៍ បានចូលរួមចំណែកក្នុងការដោះស្រាយលើបណ្តឹងតវ៉ាដែលកើតមានរវាងអ្នកប្រើប្រាស់សេវាប្រៃសណីយ៍ ជាមួយនឹងប្រតិបត្តិករប្រៃសណីយ៍។ បញ្ញត្តិដែលមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីប្រៃសណីយ៍ លើការដោះស្រាយវិវាទ និងការប្តឹងតវ៉ា នឹងបង្កើតបានជាមូលដ្ឋានគតិយុត្តកាន់តែច្បាស់សម្រាប់ដំណើរការផ្សះផ្សារឱ្យអស់លទ្ធភាពមុនពេលដែលភាគីនីមួយៗបន្តនីតិវិធីប្តឹងទៅតុលាការមានសមត្ថកិច្ច។ ដូច្នេះសេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្សះផ្សារ និងបែបបទនៃដំណើរការត្រួតពិនិត្យ និងក្រមសីលធម៌របស់មន្ត្រីក្នុងការត្រួតពិនិត្យការងារសេវាកម្មអាជីវកម្មប្រៃសណីយ៍ នឹងស្ថិតនៅក្នុងផែនការនៃការរៀបចំនាពេលខាងមុខ។
- ក.ប.ទ. បានរៀបចំអភិវឌ្ឍថ្នាលឌីជីថលសម្រាប់តាមដានបញ្ញើប្រៃសណីយ៍ ដែលមានឈ្មោះថា DGPost។ ថ្នាលនេះ ដើរតួនាទីសម្រាប់ប្រមូលព័ត៌មានបញ្ញើពីគ្រប់ប្រតិបត្តិករទាំងអស់ ពង្រឹងគុណភាពសេវា ព្រមទាំងចូលរួមការពារអ្នកប្រើប្រាស់តាមរយៈ (១) ផ្តល់ព័ត៌មានពីបញ្ញើ ពីពេលផ្ញើរហូតដល់ពេលទទួល (២) អ្នកប្រើប្រាស់អាចផ្តល់ជាមតិយោបល់ សំណូមពរ ឬការវាយតម្លៃទៅលើគុណភាពនៃសេវា (៣) ការពារការចរាចរបញ្ញើខុសច្បាប់ ដូចជាគ្រឿងញៀនជាដើម តាមសេវាបញ្ញើប្រៃសណីយ៍ (៤) ផ្តល់ព័ត៌មានស្តីពីវិស័យប្រៃសណីយ៍ដែលមានសារៈសំខាន់ដល់ដំណើរការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត ឬផែនការយុទ្ធសាស្ត្រនានា សម្រាប់ការអភិវឌ្ឍវិស័យប្រៃសណីយ៍ (៥) ជាដំណាក់កាលបន្ទាប់ នឹងជួយគាំទ្រដល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រៅពីនេះ ក្រសួងបានបង្កើតបរិយាកាសអំណោយផលគាំទ្រដល់ការធ្វើអាជីវកម្មផ្តល់សេវាប្រៃសណីយ៍តាមរយៈការរៀបចំប្រព័ន្ធស្នើសុំអាជ្ញាបណ្ណតាមអនឡាញចាប់តាំងពីឆ្នាំ២០២១ មក ដោយដំណើរការបានរលូន និងមានការគាំទ្រពីប្រតិបត្តិករប្រៃសណីយ៍លើប្រសិទ្ធភាពនៃប្រព័ន្ធនេះ។ បច្ចុប្បន្ន ក.ប.ទ. បាននិងកំពុងរៀបចំប្រព័ន្ធស្នើសុំលិខិតអនុញ្ញាតបើកសាខាប្រៃសណីយ៍តាមអនឡាញនៅមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍។
- ក.ប.ទ. បាននិងកំពុងកសាងមជ្ឈមណ្ឌលបច្ចេកវិទ្យាសហគមន៍នៅតាមវិទ្យាល័យទូទាំងប្រទេស ដើម្បីបម្រើដល់ការអប់រំតាមប្រព័ន្ធអនឡាញ និងការបញ្ជ្រាបចំណេះដឹងឌីជីថលដល់សិស្ស និងប្រជាជនក្នុងសហគមន៍ ព្រមទាំងបង្កើតបញ្ជរប្រៃសណីយ៍ សម្រាប់ចូលរួមចំណែកពង្រីក និងលើកកម្ពស់ការផ្តល់សេវាប្រៃសណីយ៍នៅមូលដ្ឋាន។

**ការបំភ្លឺលើលទ្ធផលសវនកម្ម ២. ដំណើការនៃការអនុវត្តផែនការសកម្មភាព**

ពាក់ព័ន្ធនឹងការរៀបចំផែនការសកម្មភាពលម្អិត ការរៀបចំបង្កើតក្រុមការងារអន្តរក្រសួង ការកែសម្រួលសមាភាពក្រុមការងារប្រៃសណីយ៍ ក៏ដូចជាការរៀបចំផែនការបណ្តុះបណ្តាល, ក.ប.ទ. បាននិងកំពុងយកចិត្តទុកដាក់រៀបចំអនុវត្ត រួមជាមួយនឹងការដាក់ចេញនូវផែនការដូចខាងក្រោម៖

- កន្លងមក ក.ប.ទ. បានខិតខំរៀបចំសេចក្ដីព្រាងផែនការសកម្មភាពលម្អិត រួមទាំងសូចនាករវាស់វែងសម្រាប់ការអនុវត្តជាក់ស្ដែង ដែលសេចក្ដីព្រាងនេះទើបត្រូវបានរៀបចំបញ្ចប់ និង ពិគ្រោះយោបល់ផ្ទៃក្នុងក្រសួង ក្នុងខែតុលា ឆ្នាំ២០២៤ កន្លងទៅនេះ។ ក.ប.ទ. មានផែនការរៀបចំការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់នាពេលខាងមុខ ព្រមជាមួយនឹងផែនការក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួល ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ។
- ក.ប.ទ. នឹងធ្វើបច្ចុប្បន្នភាពក្រុមការងារប្រៃសណីយ៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយបន្ថែមសមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកវិស័យប្រៃសណីយ៍ ព្រមទាំងដកចេញនូវសមាសភាពដែលបានផ្លាស់ប្ដូរភារកិច្ច និងចូលនិវត្តន៍។
- បច្ចុប្បន្ន ក.ប.ទ. កំពុងរៀបចំកែសម្រួលរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការងារគ្រប់គ្រងវិស័យក្រោមសមត្ថកិច្ចរបស់ក្រសួង។ ដូច្នេះ ក.ប.ទ. នឹងរៀបចំចាត់តាំងមន្ត្រីឱ្យបម្រើការងារប្រៃសណីយ៍ដែលមានលក្ខណៈឆ្លើយតបទៅតាមការរៀបចំកែសម្រួលរចនាសម្ព័ន្ធនេះ។
- ដោយឡែក ការបណ្ដុះបណ្ដាលមន្ត្រីកន្លងមក បានអនុវត្តតាមផែនការបណ្ដុះបណ្ដាលរបស់ក្រសួងលើជំនាញឌីជីថលមូលដ្ឋាន ព្រមទាំងទទួលបានការសហការពីប្រទេសជាដៃគូ និងស្ថាប័នអន្តរជាតិពាក់ព័ន្ធ លើការបណ្ដុះបណ្ដាលជំនាញប្រៃសណីយ៍ ដែលរួមមាន ការគ្រប់គ្រងប្រៃសណីយ៍ ការរៀបចំគោលនយោបាយបទដ្ឋានគតិយុត្តប្រៃសណីយ៍ បរិវត្តកម្មឌីជីថលក្នុងវិស័យប្រៃសណីយ៍ ប្រៃសណីយ៍អន្តរជាតិ ។ល។ ការអនុវត្តផែនការបណ្ដុះបណ្ដាលរបស់ក្រសួងលើជំនាញឌីជីថលមូលដ្ឋានមានការចូលរួមពីបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ហើយសម្រាប់ជំនាញប្រៃសណីយ៍មានកិច្ចសហការបណ្ដុះបណ្ដាលពីសហភាពប្រៃសណីយ៍សកល និងសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក។ ក្រៅពីនេះ ក.ប.ទ. ក៏មានរៀបចំកម្មវិធីបណ្ដុះបណ្ដាលប្រចាំឆ្នាំដល់មន្ត្រីនៅគ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត លើគ្រប់វិស័យក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួង ដែលរួមទាំងវិស័យប្រៃសណីយ៍ផងដែរ។

**ការបំភ្លឺលើលទ្ធផលសវនកម្ម ៣. ការបង្កើត ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តគោលនយោបាយ**

អាស្រ័យដោយហេតុថា សេចក្ដីព្រាងផែនការសកម្មភាពលម្អិតទើបតែរៀបចំបញ្ចប់ក្នុងខែតុលា ឆ្នាំ២០២៤ កន្លងទៅនេះ ដូច្នេះ កន្លងមកនៅពុំទាន់មានសូចនាករសម្រាប់វាស់វែង និងវាយតម្លៃលើការសម្រេចបាននៃសកម្មភាពនីមួយៗ ដែលជាហេតុធ្វើឱ្យពុំទាន់មានមូលដ្ឋានសម្រាប់រៀបចំប្រព័ន្ធ និងរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់ដាក់ជូនក្រសួងស្ថាប័នពាក់ព័ន្ធ។

ទោះបីជាយ៉ាងនេះក្ដី ទន្ទឹមពេលដែលអគ្គនាយកដ្ឋានប្រៃសណីយ៍បាននិងកំពុងរៀបចំសេចក្ដីព្រាងផែនការសកម្មភាពនេះ ក.ប.ទ. បានអនុវត្តសកម្មភាពជាអាទិភាពនានាដែលបម្រើឱ្យការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ ក្នុងនោះរួមមាន ការកសាងសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ការបណ្ដុះបណ្ដាលមន្ត្រីជំនាញ ការស្រាវជ្រាវ ការពង្រីកការយល់ដឹងពីវិស័យប្រៃសណីយ៍ ការពង្រឹងតួនាទីរបស់សហគ្រាសប្រៃសណីយ៍កម្ពុជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងឌីជីថលប្រៃសណីយ៍ ក៏ដូចជាកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នទទួលបន្ទុកប្រៃសណីយ៍តំបន់ និងអន្តរជាតិ។ ក.ប.ទ. នឹងបន្តខិតខំរៀបចំផែនការសកម្មភាព

លម្អិតឱ្យបានរួចរាល់ ព្រមជាមួយនឹងការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្អែកលើសូចនាករ ដែលនឹងដាក់ចេញនៅក្នុងផែនការសកម្មភាព។

## សន្និដ្ឋាន

ដូចដែលអាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញ ក.ប.ទ. ពិតជាបានខិតខំបំពេញភារកិច្ចដោយយកចិត្តទុកដាក់លើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ដោយធានាបានការសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលស្របតាមគោលនយោបាយជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។ ក.ប.ទ. នឹងបន្តអនុវត្តការងារជាអាទិភាពស្របតាមយុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យប្រៃសណីយ៍ ក្នុងនោះយកចិត្តទុកដាក់រៀបចំក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ លើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ គ្រប់គ្រងឱ្យបានល្អប្រសើរនូវការធ្វើអាជីវកម្មប្រៃសណីយ៍របស់ផ្នែកឯកជន ជំរុញការបង្កើនសមត្ថភាពរបស់សហគ្រាសប្រៃសណីយ៍កម្ពុជា សំដៅឈានទៅអនុវត្តកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថលលើការគ្រប់គ្រងក្នុងវិស័យប្រៃសណីយ៍នៃព្រះរាជាណាចក្រកម្ពុជា។

ក.ប.ទ. នឹងខិតខំអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យប្រៃសណីយ៍ សំដៅបម្រើសេវាប្រៃសណីយ៍ជូនសហគ្រាសធុរកិច្ច និងប្រជាជន ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងនវានុវត្តន៍។